ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៩២ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការកែសម្រួលក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង-ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣.អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤.អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានឃើញប្រកាសលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការកែទម្រង់ការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣៤៧ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

កែសម្រួលសមាសភាព "**ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" ។ ក្រុមការងារនេះមានភារកិច្ចក្នុងការគ្រប់គ្រង, ធានា និង ជំរុញវឌ្ឍនភាព និង ធ្វើសេចក្តីសម្រេចចិត្តលើការងារពាក់ព័ន្ធនឹងដំណើរការនៃការរៀបចំគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំហានទី២ ។

**ប្រការ២.-**

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រសិទ្ធនាមថាជា "**ប្រព័ន្ធអេហ្វអឹមអាយអេស**" និង មាននិមិត្តសញ្ញាដូចមាននៅក្នុងឧបសម្ព័ន្ធរបស់ប្រកាសនេះ ។

**ប្រការ៣.-**

ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **រស់ សីលវ៉ា** | អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣.ឯកឧត្តម **មាស សុខសេនសាន** | អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯកឧត្តមបណ្ឌិត **វង្ស ប៊ុនឥន្ទ្រាវុធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ | អនុប្រធាន |
| ៥. ឯកឧត្តម **ឈឹម សារ៉េត** | អគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | អនុប្រធាន |
| ៦. លោកបណ្ឌិត **ស្រី វុធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា | អនុប្រធាន |
| ៧. ឯកឧត្តម **មន្ត ច្រាថ្លា** | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋាន | អនុប្រធានប្រចាំការ |
| ៨. ឯកឧត្តម **សេង ស្រេង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ៩. ឯកឧត្តម **ម៉ិញ្ញ ឃានសុវណ្ណអានិច្ចាសីលា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ១០. លោក **ឈួន សំរិទ្ធិ** | អគ្គនាយករង នៃអគ្គ.សហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល | សមាជិក |
| ១១. លោកបណ្ឌិត **ឌី សុវណ្ណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ១២. លោក **គង់ វឌ្ឍនៈ** | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១៣. លោក **ឯក ចន្ថា** | ប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៤. លោក **ពៅ រិទ្ធជ័យសិទ្ធ** | ប្រធាននាយកដ្ឋាន នៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៥. លោក **និត ចំន្ទនិមិត្ត** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៦. លោក **ជា វណ្ណារ័ត្ន** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |

| | | |
|---|---|---|
| ១៧. លោក **អ៊ុន សុម៉េង** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១៨. លោក **រស់ សីហា** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១៩. លោក **តាន់ ឡូ** | អនុប្រធាននាយកដ្ឋាន នៃអគ្គ.ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ២០. លោក **ផាត់ វាសនា** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ២១. លោក **ហ៊ាន វាសនា** | អនុប្រធាននាយកដ្ឋាន នៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ២២. លោកស្រី **ឆិន សារ៉ូ** | ប្រធានការិ.នៃអគ្គ.សហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល | សមាជិក |
| ២៣. លោក **យង់ ស៊ី** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ២៤. លោក **សេង ចំរើន** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ២៥. លោក **តែ យូរ័ត្ន** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ២៦. លោក **ខេង ចាន់រស្មី** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ២៧. លោក **សាយ អ៊ាន** | ប្រធានការិយាល័យ នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ២៨. លោក **វ៉ាន ភារ៉ុល** | ប្រធានការិយាល័យ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ២៩. លោក **អ៊ុំ យុត្តារ៉ូ** | មន្ត្រីនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៣០. លោកស្រី **សុគន្ធ ចរិយា** | មន្ត្រីជំនាញជាន់ខ្ពស់ អ.គ.ហ. | សមាជិក |
| ៣១. លោក **ទី ដាវុធ** | មន្ត្រីនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៣២. លោក **ជា សុខហួរ** | ជំនួយការរដ្ឋលេខាធិការប្រធានក្រុមការងារគ្រប់គ្រងគម្រោង | សមាជិក |

**ប្រការ៤.-**

ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានលេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាក្រុមការងារស្នូលសម្រាប់គាំទ្រដល់សកម្មភាពការងារគ្រប់គ្រង និង អនុវត្តគម្រោងទាំងមូលប្រចាំថ្ងៃ ។ តួនាទី និង ភារកិច្ចរបស់លេខាធិការដ្ឋាននេះនឹងត្រូវមានចែងនៅក្នុងប្រកាសមួយដោយឡែក ។ ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ មានភារកិច្ចគន្លឹះក្នុងការធានាឱ្យបាននូវនិរន្តរភាព ក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅគ្រប់ដំណាក់កាល ដែលក្នុងនោះរួមមាន ÷

- ជំរុញឱ្យសម្រេចបាននូវលក្ខខណ្ឌគ្រឹះនានា ក្នុងការទ្រទ្រង់ដល់ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព
- ទ្រទ្រង់ និង សម្របសម្រួលដល់ការរៀបចំតម្រង់ទិសនីតិវិធីអនុវត្តការងារ ស្របតាមចក្ខុវិស័យរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំបទដ្ឋានគតិយុត្តិនានា ដែលជាប់ពាក់ព័ន្ធនឹងការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ដើរតួជាក្បាលម៉ាស៊ីនក្នុងការគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរ និង សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនានា ក្នុងការពង្រឹងការចូលរួមប្រកបដោយបុរេសកម្មដល់ដំណើរការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ពង្រឹងភាពជាម្ចាស់របស់ប្រព័ន្ធនៅតាមក្រសួង-ស្ថាប័ន និង អង្គភាពពាក់ព័ន្ធតាមរយៈ ការអនុវត្តតាមយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរ និង ផែនការប្រាស្រ័យទាក់ទង និង យន្តការធានាគុណភាពនៃការអនុវត្តគម្រោង
- ធានាភាពត្រឹមត្រូវ, ភាពប្រកួតប្រជែង និង ប្រសិទ្ធភាព នៃការដេញថ្លៃនានាសម្រាប់ការទ្រទ្រង់ដល់ការរៀបចំ, កសាង និង ដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ធ្វើការសម្របសម្រួលជាមួយ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការធានាឱ្យមានមូលនិធិគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ដល់ ដំណើរការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ធានាឱ្យបាននូវកម្មវិធីបណ្តុះបណ្តាលចាំបាច់នានា ក្នុងការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយចីរភាព
- សហការជាមួយគ្រប់អ្នកពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍនានាក្នុងការសម្រេចឱ្យបាននូវចក្ខុវិស័យនៃការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំគិតគូរលើ ផែនការរៀបចំអនុវត្តគម្រោងសម្រាប់ ការពង្រីកការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដល់គ្រប់អង្គភាពថវិកាទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ជាពិសេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសក្តានុពលលើការប្រមូលចំណូល និង ចំណាយថវិកាជាតិច្រើន ក្នុងន័យពង្រឹងការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង អនុវត្តគោលនយោបាយសារពើពន្ធឱ្យបានកាន់តែមានប្រសិទ្ធភាព
- ប្រធានក្រុមការងារមានសិទ្ធិចេញសេចក្តីសម្រេច ក្នុងការបង្កើតក្រុមការងារផ្នែកតូចៗតាមការចាំបាច់សម្រាប់ជំរុញដល់ការអនុវត្តគម្រោងឱ្យប្រព្រឹត្តទៅបានប្រកបដោយប្រសិទ្ធភាព រលូន និង ទាន់ពេលវេលា
- ផ្តល់នូវធនធានមនុស្សគ្រប់គ្រាន់ជូន លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីអភិវឌ្ឍ និង ទ្រទ្រង់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យដំណើរការបានប្រកបដោយប្រសិទ្ធភាព និង មាននវានុវត្តភាព ។

**ប្រការ៥.-**

សមាសភាពក្រុមការងារ ដែលជាមន្ត្រីរាជការនៅក្នុងក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងត្រូវទទួលបានការលើកទឹកចិត្តនានា រួមមាន÷

- ការលើកទឹកចិត្តផ្នែកលាភការពីមូលនិធិប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមអត្រាពិសេសដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៩ ទៅ
- ការលើកទឹកចិត្តក្នុងការផ្តល់មុខងារសមស្របនៅពេលត្រឡប់ទៅអង្គភាពដើមវិញ ។

**ប្រការ៦.-**

អនុប្រធានក្រុមការងារ ដូចមានចែងក្នុងប្រការ៣ តាមការប្រគល់សិទ្ធិពីប្រធាន អាចកោះប្រជុំ និង ដឹកនាំការងារដើម្បីសម្រេចបានតាមភារកិច្ចរបស់ក្រុមការងារ ។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលខ្ទឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

- ផ្ទេរតួនាទី និង ភារកិច្ចទទួលខុសត្រូវរបស់ខ្លួនជូន នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅពេលបញ្ចប់ការអនុវត្តគម្រោងដោយជោគជ័យ ដោយត្រូវផ្លាស់ប្តូរពីសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មកជាសកម្មភាពការងារប្រចាំថ្ងៃវិញ ដើម្បីធានានិរន្តរភាព និង ភាពជាម្ចាស់នៃការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ៤.-**

សមាសភាពក្រុមការងារ ដែលជាមន្ត្រីរាជការនៅក្នុងលេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងត្រូវទទួលបានការលើកទឹកចិត្តនានា រួមមាន÷

- ការលើកទឹកចិត្តផ្នែកលាភការពីមូលនិធិប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមអត្រាពិសេសដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៩ តទៅ
- ការលើកទឹកចិត្តក្នុងការផ្តល់មុខងារសមស្របនៅពេលត្រឡប់ទៅអង្គភាពដើមវិញ ។

**ប្រការ៥.-**

អនុប្រធានលេខាធិការដ្ឋាន, ប្រធានផ្នែក, ប្រធានផ្នែកបច្ចេកទេស, អនុប្រធានផ្នែក ដូចមានចែងក្នុងប្រការ២ តាមការប្រគល់សិទ្ធិពីប្រធានលេខាធិការដ្ឋានអាចកោះប្រជុំ និង ដឹកនាំការងារ ដើម្បីសម្រេចបានតាមភារកិច្ចរបស់លេខាធិការដ្ឋាន ។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាមានខ្លឹមសារដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និង ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ខាងលើត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ[illegible] ខែមាឃ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៩

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

***ចម្លងជូន៖***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង-ស្ថាប័ន*
- *ដូចប្រការ៧*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*